Australian Government
Department of Immigration and Citizenship

# ពត៌មានផ្ទាល់ខ្លួនប្រមូលសំរាប់ ការផ្គត់ផ្គង់កម្មវិធីភាសារអង់គ្លេសសំរាប់ជនពេញវ័យ (AMEP)

ស្ថាប័នផ្តល់កិច្ចបំរើ AMEP ត្រូវបានស្នើសុំអោយប្រមូលពត៏មានផ្តាល់ខ្លួនសំរាប់ក្រសួងអន្តោប្រវេសន៍និងការចូលសញ្ជាតិ (ក្រសួង) AMEP។ ការប្រមូល ត្រូវបានអនុញ្ញាតនៅក្រោមភាគ២នៃច្បាប់អន្តោប្រវេសន៍ឆ្នាំ១៩៥៨។

ពត៏មានដែលប្រមូល អាចនឹងត្រូវបានលាតត្រដាងដល់ភ្នាក់ងាផ្សេងៗ ឬអង្គការ ទាំងឡាយទៀតសំរាប់គោលបំណង នៃការចាត់ចែងកម្មវិធីរដ្ឋាភិបាលរួមទាំងសេវាកម្មផ្សេងៗរួមមាន ៖

- មជ្ឈមណ្ឌលមើលថែរកុមារ ដើម្បីផ្តល់អោយការមើលថែរកុមារសំរាប់ អតិថិជនដែលមាន សិទ្ធ AMEP
- និយោជិកជាប់ទាក់ទងនៅក្នុង AMEP កម្មវិធីតាំងលំនៅភាសាផ្លូវឆ្ពោះទៅកាន់ការងារនិងហ្វឹកហ្វឺន
- ស្ថាប័នផ្តល់កិច្ចបំរើដែលជាប់កិច្ចសន្យាមួយក្រសួង ដើម្បីចាត់ចែងកិច្ច បំរើផ្តល់ទិសដៅសំរាប់ជនដែលទើបមកដល់ថ្មីៗ
- ក្រសួងរដ្ឋាភិបាលទាំងអស់រួមមាន
    - Centrelink ដែលចាត់ចែងប្រាក់ឧបត្ថម្ភនិងប្រាក់បំណាច់
    - ក្រសួងការងារនិងទំនាក់ទំនងកន្លែងធ្វើការ (DEEWR)
    - ស្ថាប័នផ្តល់កិច្ចបំរើដែលជាប់សន្យាដើម្បីផ្គត់ផ្គងរាល់សេវាកម្មដំណាងអោយ DEEWR រួមទាំងសេវាកម្មការងារអូស្ត្រាលីនិងកិច្ចបំរើការងារសំរាប់មនុស្សពិការភាពក
- ក្រសួងប៉ូលីសសហព័ន្ធ រដ្ឋ និងនដែនដីដើម្បីជួយសង្កេតការណ៍ រឺស្ថានភាពក្នុងគ្រាបន្ទាន់

បន្ថែមពីនេះទំរង់៩៩៣iការពារសុវត្ថិភាពពត៏មានផ្ទាល់ខ្លួនរបស់លោកអ្នកផ្តល់ជូនពត៏មានរបស់ភ្នាក់ងារទាំងឡាយដែលពត័មានផ្ទា ល់ខ្លួនរបស់លោកអ្នកអាចបញ្ចេញប្រាប់។

គំរូរ ៩៩៣i អាចទទួលយកបានពីវ៉ិបសាយរបស់ក្រសួង www.immi.gov.au/allforms/ រឺការិយាល័យមួយរបស់ក្រសួង រឺ ប្រតិភូការបរទេសអូស្ត្រាលី។

## សិទ្ធិរបស់លោកអ្នក

ប្រសិនបើលោកអ្នកជឿថាស្ថាប័នផ្តល់កិច្ចបំរើឬក្រសួងបានប្រមូល រឺ ចាត់ចែងពត៏មានផ្ទាល់ខ្លួនរបស់លោកអ្នកមិនត្រឹមត្រូវ សូមសរសេរសំបុត្រទៅកាន់

The Director

Freedom of Information and Privacy Policy Section

Department of Immigration and Citizenship

PO Box 25

BELCONNEN ACT 2616

Or e-mail privacy@immi.gov.au

**បណ្តឹងតវ៉ារបស់លោកអ្នកនឹងត្រូវបានស៊ើបអង្កេតហើយលោកអ្នកនឹងត្រូវបានគេជំរាបប្រាប់លទ្ធផល។**